

# តើមានសេវាអ្វីខ្លះសម្រាប់កុមារគ្រប់អាយុ ចូលរៀន និងគ្រួសារ?





HARBOR
REGIONAL
CENTER

ជាញឹកញាប់ អតិថិជនរបស់យើង
ឬឪពុកម្តាយ/សមាជិកគ្រួសារបានស្នើសុំព័ត៌មាន
អំពីសេវាដែលមាន។ យើងបានរៀបចំបញ្ជីនេះដើ
ម្បីផ្តល់ជូនអ្នកនូវទិដ្ឋភាពទូទៅអំពីសេវាទាំងនេះ។
សូមចងចាំថា សេវាត្រូវបានកំណត់ទៅតាមបុគ្គលម្នា
ក់ៗ។ សេវាត្រូវតែកំណត់ទៅតាមការចាំបាច់នៅលើផែ
នការផ្តោតលើបុគ្គល (IPP) និងត្រូវផ្តល់ជូនស្របទៅតាម
គោលនយោបាយសេវារបស់ មជ្ឈមណ្ឌលតំបន់ Harbor
ដែលបានដាក់នៅលើវេបសាយតរបស់យើង។

សេវាមួយចំនួនត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារសហគមន៍
ឧបត្ថម្ភដោយមូលនិធិសាធារណៈ ដូចជាខណ្ឌសាលា
Medi-Cal។ល។ និងមួយចំនួនទៀតទទួលបានមូលនិធិពី
HRC បន្ទាប់ពីយើងបានបំពេញតាមលក្ខខ
ណ្ឌស្វែងរកធនធានមូលនិធិដែលអា
ចមានផ្សេងៗទៀតទាំងអស់។

យើងដឹងថា អ្នកចង់ដឹងអំពី
ប្រភេទសេវាផ្សេងៗដែល
មានដើម្បីឲ្យអ្នកអាចក្លា
យជាអ្នកចូលរួមដែលទ
ទួលបានព័ត៌មានគ្រប់គ្
រាន់នៅក្នុងដំណើរកា
ររៀបចំផែនការសេវា។
ខាងក្រោមគឺជាបញ្ជីសេវា
និងការគាំទ្រមួយចំនួនដែល
ជាទូទៅត្រូវបានណែនាំសម្
រាប់កុមារគ្រប់អាយុចូលរៀន
(3-22) ក៏ដូចជាក្រុមគ្រួសាររបស់
ពួកគេផងដែរ។



## សេវាដែលផ្តល់ដោយបុគ្គលិក HRC

### ការវាយតម្លៃ និងការពិគ្រោះយោបល់

អ្នកសម្របសម្រួលសេវារបស់អ្នកអាចរៀបចំការជួបប្រជុំជាមួយអ្នកជំនា
ញរបស់ HRC ឬក្រុមពហុវិស័យដើម្បីវាយតម្លៃតម្រូវការកូនរបស់អ្នក ក៏ដូ
ចជាផ្តល់ជូនអ្នកនូវសេវាពិគ្រោះយោបល់ផងដែរ។ ការវាយតម្លៃ និងការ
ពិគ្រោះយោបល់អាចជួយនៅក្នុងការផ្តល់ និងបញ្ជាក់ការធ្វើរោគវិនិច្ឆ័យ
កំណត់ប្រភេទសេវា និងការគាំទ្រដែលត្រូវការ
កំណត់តម្រូវការសុខភាពគ្រួសារ និងសុខភាពផ្លូវចិត្ត គាំទ្រសិទ្ធិទទួល
បានអត្ថប្រយោជន៍ដែលឧបត្ថម្ភដោយមូលនិធិសាធារណៈ។ល។

HRC មានអ្នកជំនាញដែលមានឯកទេសផ្នែកអភិវឌ្ឍន៍កុមារតូច
ការព្យាបាលលើការនិយាយ ការព្យាបាលដោយចលនា ការអប់រំ
ចិត្តវិទ្យា អន្តរាគមន៍ចំពោះឥរិយាបថ វេជ្ជសាស្ត្រ សេនេទិច ការថែទាំ
អនាម័យមាត់ធ្មេញ ឱសថសាស្ត្រ អាហារូបត្ថម្ភ បច្ចេកវិទ្យាជំនួយ
សុខភាពផ្លូវចិត្ត អត្ថប្រយោជន៍ហិរញ្ញវត្ថុ និងសុខភាព ច្បាប់
ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ សេវាពេលថ្ងៃសម្រាប់មនុស្សធំ
និងជម្រើសផ្សេងៗសម្រាប់ការរស់នៅ។

### ការគាំទ្រផ្នែកអប់រំ

អ្នកសម្របសម្រួលសេវាអាចផ្តល់ការគាំទ្រដល់គ្រួសា
រតាមរយៈការពិភាក្សាអំពីការប្រជុំផែនការអប់រំលក្ខ
ណៈបុគ្គលនៅពេលខាងមុខ (IEP) កំណត់អំពីតម្រូវការ
ការព្រួយបារម្ភ និងគោលដៅ ក៏ដូចជា ការជួយឪ
ពុកម្តាយដើម្បីត្រៀមចូលរួមនៅក្នុងការប្រជុំ IEP។
ប្រសិនបើចាំបាច់ អ្នកសម្របសម្រួលសេវាអាចរៀបចំគ្រួ
សារឲ្យធ្វើការពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកអប់រំរ
បស់HRC។ អ្នកសម្របសម្រួលសេវាក៏អាចចូលរួមនៅក្នុងការប្
រជុំ IEP ផងដែរប្រសិនបើមានការអញ្ជើញពីឪពុកម្តាយដើម្បីផ្តល់
ការគាំទ្រ។

### ការគាំទ្រគ្រួសារ

នៅឯមជ្ឈមណ្ឌលតំបន់ Harbor យើងជឿជាក់ថា ប្រព័ន្ធគាំទ្រល្អប្រសើរគឺជាអត្ថប្រយោជន៍ដ៏សំខាន់សម្រាប់គ្
រួសារ។ បណ្តាញព័ត៌មាន និងការគាំទ្រផ្តល់ជូនគ្រួសារនូវមូលដ្ឋានដ៏ល្អប្រសើរសម្រាប់ស្វែងរកប្រព័ន្ធសេវា ធ្វើការជ្
រើសរើសក្រោយទទួលបានព័ត៌មានគ្រប់គ្រាន់ និងទទួលបានគុណភាពជីវិតកាន់តែល្អប្រសើរសម្រាប់គ្រួសារដែលស្ថិតក្នុងដំណា
ក់កាលវិវត្តទៅរកពិការភាព។ ការគាំទ្រត្រូវបានផ្តល់ជូននៅក្រោមរូបភាពក្រុមគាំទ្រឪពុកម្តាយ កម្មវិធីឪពុកម្តាយបង្ហាត់ឪពុកម្តាយនិងក្លិបបងប្
អូន HRC។ សម្រាប់ព័ត៌មានលម្អិតអំពីជម្រើសគាំទ្រគ្រួសារទាំងនេះ សូមចូលមើលវេបសាយត៍របស់ HRC (www.harborrc.org/resources/family)
ពិភាក្សាជាមួយអ្នកសម្របសម្រួលសេវារបស់អ្នក ឬអញ្ជើញទៅកាន់មជ្ឈមណ្ឌលធនធាននិងបច្ចេកវិទ្យាជំនួយរបស់ HRC នៅ Torrance ឬ Long
Beach។




### បទបង្ហាញផ្តល់ព័ត៌មានសម្រាប់ឪពុកម្តាយ/គ្រួសារ

ថ្នាក់សិក្សា និងបទបង្ហាញផ្តល់ព័ត៌មានសម្រាប់គ្រួសារត្រូវបានផ្តល់ជូនរយៈពេលពេញ
មួយឆ្នាំដែលផ្តោតទៅលើប្រធានបទផ្សេងៗដូចជា ការបង្កើតកាលវិភាគសកម្មភាព
កម្មវិធីអត្ថប្រយោជន៍ផ្សេងៗដូចជា ប្រាក់ចំណូលរបបសន្តិសុខជំនួយ (SSI)
និងសេវាគាំទ្រតាមផ្ទះ (IHSS)ឥណទានតម្រូវការពិសេស ភាពជាអ្នកថែរក្សា
ការផ្លាស់ប្តូរទៅវ័យយុវភាព ជម្រើសសម្រាប់ការរស់នៅផ្សេងៗ។ល។ HRC ក៏ផ្តល់ជូ
នផងដែរនូវជំនួយសេវាបកប្រែ ការថែទាំកុមារ និងការធ្វើដំណើរនៅក្នុងការធ្វើបទ
បង្ហាញដែលបានកំណត់ ប្រសិនបើចាំបាច់ដើម្បីឲ្យឪពុកម្តាយអាចចូលរួមបាន។

បញ្ជីបទបង្ហាញនៅពេលខាងមុខអាចរកបាននៅក្នុងប្រតិទិនបណ្តុះបណ្តាល
និងកម្មវិធីរបស់ HRC ក៏ដូចជានៅក្នុងប្រតិទិនវេបសាយត៍របស់យើងផងដែរ។

### ឱកាសសម្រាប់ភាពជាអ្នកដឹកនាំ

HRC ផ្តល់ជូននូវឱកាសស្ម័គ្រចិត្តសម្រាប់ឪពុកម្តាយ/សមាជិកគ្រួសារដើម្
បីចូលរួមនៅក្នុងគណៈកម្មាធិការ HRC កម្មវិធីផ្សេងៗ ក៏ដូចជាអភិបាលកិច្ច
ទៅលើគណៈកម្មការប្រតិសិទ្ធិជនផងដែរ។

## មជ្ឈមណ្ឌលធនធាន និងបច្ចេកវិទ្យាជំនួយ

មជ្ឈមណ្ឌលធនធាន និងបច្ចេកវិទ្យាជំនួយរបស់ HRC ផ្តល់ជូននូវការគាំទ្រតាមរយៈការផ្តល់ព័ត៌មាន ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកវិទ្យា និងតាមរយៈការគាំទ្រពីឪពុកម្តាយផ្សេងទៀត។ សេវារួមមានបណ្ណាល័យពហុប្រព័ន្ធផ្សព្វផ្សាយទូលំទូលាយ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់បច្ចេកវិទ្យាជំនួយបណ្ណាល័យឲ្យខ្ចីប្រដាប់ប្រដារក្មេងលេង ព្រមទាំងក្រុមគាំទ្រគ្រួសារ និងបងប្អូន។

## ការសម្របសម្រួលសេវា

ការរៀបចំផែនការបុគ្គលជាមួយគ្រួសារ ការបញ្ជូនទៅ ឬនិងការសម្របសម្រួលសេវាដែលមានពីទីភ្នាក់ងារសហគមន៍ ឬអ្នកផ្តល់សេវាដែលឧបត្ថម្ភមូលនិធិដោយមជ្ឈមណ្ឌលតំបន់ ការគាំទ្រសម្រាប់ការទទួលបានសេវាសមស្រប និងការពិនិត្យមើលជាប្រចាំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ឬញឹកញាប់ជាងនេះប្រសិនបើចាំបាច់។

## ការឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង

HRC រក្សាប្រព័ន្ធឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង។ ប្រសិនបើអ្នកមានស្ថានភាពត្រូវការជំនួយបន្ទាន់ និងត្រូវការទាក់ទងទៅHRC ក្រៅម៉ោងធ្វើការធម្មតា គឺនៅមានអ្នកចាំទទួលសំណើរបស់អ្នក។

## សេវានានាដែល HRC ទិញពីកម្មវិធី និងពេទ្យពិនិត្យជំងឺនៅក្នុងសហគមន៍

## ការថែទាំក្រោយម៉ោងសិក្សា

សម្រាប់ឪពុកម្តាយធ្វើការរបស់សិស្សដែលជាប់រៀននៅសាលា និងមិនអាចទទួលធនធានថែទាំពេលថ្ងៃធម្មតាបាន នោះ HRC អាចផ្តល់ការគាំទ្រថែទាំពេលថ្ងៃនៅមណ្ឌលថែទាំពេលថ្ងៃធម្មតា ឬនៅផ្ទះ ការថែទាំនៅក្នុងកម្មវិធីថែទាំឯកទេស នៅក្រោយម៉ោងសិក្សា ឬនៅអំឡុងម៉ោងសម្រាកកម្មវិធីក្រៅម៉ោងសិក្សា។

## សេវាឥរិយាបថ

សេវាឥរិយាបថត្រូវបានរៀបចំឡើងដើម្បីជួយដល់ឪពុកម្ដាយអ្នកផ្តល់សេវាថែទាំនៅក្នុងការអនុវត្តគោលការណ៍ឥរិយាបថ និងបង្រៀនជំនាញថ្មីៗដោយប្រើប្រាស់ឧទាហរណ៍លក្ខណៈបុគ្គល និងអនុវត្តជាក់ស្តែង។ វគ្គផ្សេងៗសម្រាប់ឪពុកម្តាយ កុមារ និងក្មេងជំទង់ផ្តល់នូវឱកាសក្នុងការលើកកម្ពស់ការចូលរួមក្នុងសង្គម និងសុវត្ថិភាពនៅក្នុងសហគមន៍។

## សេវាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ

HRC អាចផ្តល់សេវាបកប្រែផ្ទាល់មាត់នៅក្នុងការប្រជុំជាមួយ HRC និងការបកប្រែសំណៅឯកសារ (ផែនការផ្តោតលើបុគ្គល) ពីភាសាអង់គ្លេសទៅជាភាសាកំណើតរបស់អតិថិជន/គ្រួសារ។

## សេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំ

ដើម្បីបំពេញតម្រូវការសេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំសម្រាប់អតិថិជនដែលពុំមានធនធានថែទាំសុខភាពផ្សេងទៀតដូចជាធានារ៉ាប់រងឯកជន ឬ Medi-Calនោះនឹងអាចមានការផ្តល់ជំនួយតាមការចាំបាច់។ ការវាយតម្លៃលើការថែទាំ ឬការថែទាំសុខភាពតាមផ្ទះអាចផ្តល់ជូនដើម្បីគាំទ្រគ្រួសារនៅក្នុងការបំពេញតម្រូវការថែទាំសុខភាពពិសេស។

## បរិក្ខារ និងសម្ភារវេជ្ជសាស្ត្រ

HRC អាចផ្តល់ការវាយតម្លៃទៅលើតម្រូវការវេជ្ជសាស្ត្រ និងផ្តល់ជំនួយនៅក្នុងការកំណត់ធនធានសហគម៍ន៍ផ្សេងៗដូចជា Medi-Cal ជាដើម។ ប្រសិនបើពុំមានធនធានទាំងនេះទេ យើងអាចចូលរួមចំណែកនៅក្នុងការទិញសម្ភារ និងបរិក្ខារផ្សេងៗ ដូចជាកៅអីរុញ គ្រែបច្ចេកទេសជាដើម។ល។



## ការថែទាំជំនួសបណ្តោះអាសន្ន

ជំនួយបណ្តោះអាសន្នពីការថែទាំ និងគ្រប់គ្រងអាចផ្តល់ជូនដល់ឪពុកម្តាយ ឬអ្នកផ្តល់សេវាថែទាំបឋមផ្សេងៗទៀតសម្រាប់អតិថិជនដែលមានកង្វះខាតធំក្នុងការថែទាំខ្លួន តម្រូវការវេជ្ជសាស្ត្រជាប្រចាំ ឬបញ្ហាឥរិយាបថផ្សេងៗ។ សេវាថែទាំជំនួសបណ្តោះអាសន្នត្រូវបានផ្តល់ជូននៅតាមផ្ទះរបស់អតិថិជន/គ្រួសារដោយបុគ្គលិករបស់ទីភ្នាក់ងារថែទាំតាមផ្ទះ។ នៅក្នុងការថែទាំជំនួសបណ្តោះអាសន្នកំណត់ដោយគ្រួសារ សមាជិកគ្រួសារអាចបញ្ជូនទៅមិត្តភក្តិ ឬសាច់ញាតិដែលខ្លួនទុកចិត្តដែលបម្រើការងារឲ្យទីភ្នាក់ងារថែទាំតាមផ្ទះ ដើម្បីផ្តល់ការថែទាំជំនួសបណ្តោះអាសន្នសម្រាប់សមាជិកគ្រួសាររបស់អ្នក។ កាថែទាំជំនួសបណ្តោះអាសន្នក្រៅផ្ទះអាចផ្តល់ជូននៅតាមផ្ទះដែលមានអាជ្ញាប័ណ្ណ ប្រសិនបើមាន។

## ការបណ្តុះបណ្តាលជំនាញសង្គមសម្រាប់កុមារ និងក្មេងជំទង់ដែលមានបញ្ហាវិសាលគមន៍មនោវិក័ត



បច្ចុប្បន្នសេវានេះត្រូវបានផ្តល់ជូនសម្រាប់កុមារដែលអាយុចូលរៀន (ពីបួនរហូតដល់12 ឆ្នាំ) និងក្មេងជំទង់ (12-17 ឆ្នាំ) ដើម្បីអភិវឌ្ឍ និងអនុវត្តជំនាញសង្គម និងដើម្បីគាំទ្រដល់ការចូលរួមនៅក្នុងបរិយាកាសសហគមន៍រួមក៏ដូចជាសកម្មភាពផ្សេងៗផងដែរ។ កម្មវិធីនឹងដាក់បញ្ចូលការចូលរួមរបស់ឪពុកម្តាយដើម្បីគាំទ្រដល់ការអភិវឌ្ឍរបស់កុមារនិងក្មេងជំទង់ រួមទាំងការរៀបចំផែនការឱកាសអនុវត្តជំនាញផ្សេងៗនៅក្នុងសហគមន៍ផងដែរ។

## កម្មវិធីព្យាបាលបញ្ហានិយាយ និងភាសា ការព្យបាលដោយចលនា ការព្យាបាលស្តារកាយសម្បទា ការព្យាបាលសុខភាពឥរិយាបថសម្រាប់បញ្ហាវិសាលគមន៍មនោវិក័ត

ប្រសិនបើកូនរបស់អ្នកត្រូវការការព្យាបាលលក្ខណៈបុគ្គល ឬសេវាព្យាបាលសុខភាពឥរិយាបថដើម្បីព្យាបាលមនោវិក័តនោះវិធីព្យាបាលទាំងនេះនឹងត្រូវផ្តល់ជូនជាទូទៅតាមរយៈសាលាដែលជាផ្នែកមួយនៃកម្មវិធីអប់រំសរុប។ ប្រសិនបើសេវាបន្ថែមនៅក្រៅកម្មវិធីសាលាត្រូវបានចាត់ទុកថាមានភាពចាំបាច់ផ្នែកវេជ្ជសាស្រ្ត នោះអ្នកសម្របសម្រួលសេវារបស់អ្នកអាចណែនាំអ្នកនៅក្នុងការទទួលបានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិតរបស់អ្នក និងទទួលបានសេវាទាំងនេះតាមរយៈផែនការធានារ៉ាប់រងសុខភាពឯកជនរបស់អ្នក ឬតាមរយៈ Medi-Cal។

មជ្ឈមណ្ឌលថ្នាក់តំបន់ក៏អាចជួយគ្រួសារផ្នែកមូលនិធិដើម្បីចំណាយទៅលើផ្នែកដែលគ្មានធានារ៉ាប់រង ធានារ៉ាប់រងរួមគ្នា ឬទូទាត់រួមគ្នានៅពេលផែនការធានារ៉ាប់រងសុខភាពឯកជននឹងផ្តល់ការធានាសម្រាប់សេវាទាំងនេះ ហើយគ្រួសារអាចទទួលបានដោយផ្អែកទៅលើកម្រិតប្រាក់ចំណូលទាប។

## មធ្យោបាយដឹកជញ្ជូន

ដោយផ្អែកលើតម្រូវការ និងសមត្ថភាពបុគ្គល/គ្រួសារ HRC អាចជួយភ្ជាប់គ្រួសារទៅនឹងសេវាដឹកជញ្ជូនសមស្របនៅក្នុងសហគមន៍ ដូចជា សេវាដឹកជញ្ជូនសាធារណៈ សេវាដឹកជញ្ជូនរួមរបស់សហគមន៍ជាដើម។ HRC ក៏ផ្តល់ជូនផងដែរនូវជំនួយផ្នែកដឹកជញ្ជូននៅពេលចាំបាច់ដើម្បីឲ្យអតិថិជនឬឪពុកម្តាយអាចចូលរួមនៅក្នុងបទបង្ហាញផ្តល់ព័ត៌មានរបស់ HRC ឬសេវាដែលបានកំណត់នៅក្នុងផែនការផ្តោតលើបុគ្គល។

# ការផ្លាស់ប្តូរទៅវ័យយុវភាព

## ជម្រើសផ្សេងៗសម្រាប់ការរស់នៅ

សម្រាប់អតិថិជនដែលមិនអាចរស់នៅជាមួយក្រុមគ្រួសាររបស់ខ្លួន ឬដោយខ្លួនឯងបាន នោះផ្ទះដែលមានអាជ្ញាប័ណ្ណ ឬផ្ទះទទួលចិញ្ចឹមអាចផ្តល់ជូនសេវាថែទាំសម្រាប់បុគ្គលម្នាក់ៗ ការគាំទ្រផ្នែកសុខភាព និងឥរិយាបថ ក៏ដូចជា ជួយសម្រួលដល់ផ្ទះទូទៅនៅក្នុងសហគមន៍ផងដែរ។ ជម្រើសរស់នៅទាំងនេះមានចំនួនកំណត់សម្រាប់អតិថិជនដែលមានអាយុក្រោម18 ឆ្នាំ។

## ការស្រាវជ្រាវគម្រោង/កម្មវិធីបទពិសោធន៍ការងារនៅសាលារៀន

នៅពេលសិស្សត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីអន្តរកាលសាលា ពួកគេអាចនឹងត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីបទពិសោធន៍ការងារដែលពួកគេអាចទទួលបានបទពិសោធន៍ការងារមួយចំនួន និងរៀនសូត្រអំពីរបៀបអនុវត្តដោយខ្លួនឯងនៅក្នុងបរិយាកាសការងារ។ អ្នកសម្របសម្រួលសេវា HRC របស់អ្នកអាចជួយអ្នកក្នុងការស្វែងរកកម្មវិធីអន្តរកាលដែលស្រុកសាលារបស់អ្នកបានផ្តល់ជូននៅអំឡុងដំណើរការរៀបចំផែនការអន្តរកាលបុគ្គលរបស់សាលា។

ការស្រាវជ្រាវគម្រោងគឺជាកម្មវិធីថ្នាក់ជាតិដែលលើកកម្ពស់បទពិសោធន៍ការងារនៅក្នុងបរិយាកាសសហគមន៍សម្រាប់អ្នកដែលមានភាពខ្សោយផ្នែកការលូតលាស់។ បច្ចុប្បន្នHRC សហការជាមួយ ស្រុកសាលា Los Angeles Unified School District, Kaiser South Bay Medical Center និង Best Buddies ដើម្បីផ្តល់កម្មវិធីស្រាវជ្រាវគម្រោងនៅក្នុងតំបន់នេះ។ តាមរយៈកម្មវិធីនេះ សិស្សដែលស្ថិតក្នុងឆ្នាំចុងក្រោយនៃអន្តរកាលសាលាទទួលបានបទពិសោធន៍ការងារជាក់ស្តែង និងការអនុវត្តនៅទីតាំងការងារផ្ទាល់ដើម្បីត្រៀមខ្លួនអនុវត្តការងារឲ្យបានកាន់តែប្រសើរបន្ទាប់ពីរៀនចប់នៅសាលា។

*សូមមើលពិនិត្យបញ្ជីតើមានសេវាអ្វីខ្លះសម្រាប់មនុស្សពេញវ័យHRCដើម្បីសិក្សាបន្ថែមអំពីសេវាដែលមានបន្ទាប់ពីអតិថិជនរៀនចប់នៅសាលា។*

HARBOR REGIONAL CENTER
HARBOR DEVELOPMENTAL DISABILITIES FOUNDATION, INC.
21231 HAWTHORNE BLVD., TORRANCE, CA 90503
(310) 540-1711 • www.harborrc.org

May 2017